ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**KINGDOM OF CAMBODIA**
***Nation - Religion - King***

លេខ ១១៣៣ ព.ណ [illegible]

ភ្នំពេញ, ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១៥

**ជម្រាបមក**

**លោកនាយកក្រុមហ៊ុន ខួច ជ្រេយ្ហួន អ៊ិនធើណេសិនណល ខូ អិលធីឌី**

**កម្មវត្ថុ:** ការកត់ត្រាទទួលស្គាល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាកគ្រឿងសម្អាងរួមមាន: ក្រែមលាបមាត់ ម្សៅផាត់ធ្វើស្រមោលភ្នែក ថ្នាំលាបក្រចក ម្សៅលាបមុខជាឈុត ខ្មៅដៃគូរចិញ្ចើម ម្សៅសម្រាប់តុបតែងកាយ ទឹកអប់ ក្រែមសម្រាប់សំអាងកាយ ថ្នាំរាវសម្រាប់គោលដៅសំអាងកាយ ក្រែមសម្រាប់ធ្វើសរសៃ លេសម្រាប់សំអាតកាយ ថ្នាំលាបរោមភ្នែក ទឹកលាបសក់ ប្រេងលាបសក់ ប្រេងខ្យល់ ម្សៅទ្រនាប់ សាប៊ូកក់សក់ លេលាបបន្ទាប់ពីកោរពុកមាត់ សាប៊ូដុសខ្លួន បន្សំផ្អែកសំអាងកាយសម្រាប់ការពារស្បែក និងសំអាងកាយពាក់ម៉ាក Cathy Doll និង Cathy Choo ក្នុងព្រះរាជាណាចក្រកម្ពុជា របស់ក្រុមហ៊ុន **ខួច ជ្រេយ្ហួន អ៊ិនធើណេសិនណល ខូ អិលធីឌី** ។

**យោង:**
- មាត្រា ៣ និងមាត្រា ១១ នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- លិខិតរបស់ក្រុមហ៊ុន **ខួច ជ្រេយ្ហួន អ៊ិនធើណេសិនណល ខូ អិលធីឌី** ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៥
- លិខិតប្រគល់សិទ្ធិផ្តាច់មុខរបស់ក្រុមហ៊ុន KARMARTS PUBLIC COMPANY LIMITED ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៥
- វិញ្ញាបនបត្រចុះបញ្ជីម៉ាក Cathy Doll លេខចុះបញ្ជី KH/៤៣៤០៣/១៣ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៣
- វិញ្ញាបនបត្រចុះបញ្ជីម៉ាក Cathy Choo លេខចុះបញ្ជី KH/៤៣៤០០/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១៣ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោកនាយកថា ក្រសួងពាណិជ្ជកម្ម ឯកភាពកត់ត្រាទទួលស្គាល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាកគ្រឿងសម្អាងម៉ាក Cathy Doll និង Cathy Choo ក្នុងព្រះរាជាណាចក្រកម្ពុជា របស់ក្រុមហ៊ុន **ខួច ជ្រេយ្ហួន អ៊ិនធើណេសិនណល ខូ អិលធីឌី** ដែលទទួលបានពីក្រុមហ៊ុន KARMARTS PUBLIC COMPANY LIMITED ដូចមានចែងក្នុងលិខិតប្រគល់សិទ្ធិផ្តាច់មុខរបស់ម្ចាស់ម៉ាក ដែលក្រសួងបានតម្កល់ទុករួចហើយ ។

លិខិតទទួលស្គាល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាកនេះ មានសុពលភាពត្រឹមថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៧ គិតចាប់ពីក្រោយថ្ងៃចុះហត្ថលេខា ចំនួន ៩០(កៅសិប) ថ្ងៃ ហើយអាចនឹងត្រូវបាត់បង់សុពលភាពជាស្វ័យប្រវត្តិវិញ មុនកាលបរិច្ឆេទផុតកំណត់ខាងលើ ប្រសិនបើមានការជូនដំណឹងអំពីការបញ្ចប់សិទ្ធិពីក្រុមហ៊ុន KARMARTS PUBLIC COMPANY LIMITED ដែលជាម្ចាស់ម៉ាក Cathy Doll និង Cathy Choo នេះ។

នីតិបុគ្គលដែលទទួលបានសិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាកនៃផលិតផលម៉ាក Cathy Doll និង Cathy Choo នេះ ត្រូវបោះពុម្ពផ្សាយលិខិតទទួលស្គាល់ក្នុងទំព័រខាងមុខរបស់សារព័ត៌មានល្បីៗភ្លាមយ៉ាងតិចចំនួន ៣(បី) លេខជាប់ៗគ្នា និងត្រូវអនុវត្តឲ្យបានត្រឹមត្រូវនូវលិខិតបទដ្ឋានច្បាប់ និងសារាចរណែនាំរបស់រាជរដ្ឋាភិបាលទាក់ទងនឹងការគ្រប់គ្រងសិទ្ធិផ្តាច់មុខ ក្នុងការប្រើប្រាស់ម៉ាក ។

អាស្រ័យហេតុនេះ សូមលោកនាយកក្រុមហ៊ុន ជ្រាបជាព័ត៌មាន ។

**ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**រដ្ឋលេខាធិការ**

**អ៊ុក-ប្រជា**

**ចម្លងជូន:**
- ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង**
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ **គាត ឈន់**
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គនាយកដ្ឋានកាំកុងត្រូល
- អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា
- អគ្គនាយកដ្ឋានពន្ធដារ
- ឯកសារ - កាលប្បវត្តិ

ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ:(៨៥៥)-២៣ ៨៦៦ ៤៦៩
*Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA*
*Phone/Facsimile: (855)-23 866 469*